១៥/៥/២០២៣ ប័ណ្ណព័ត៌មាន លេខ ១៣

# SPRING PARKS PRIMARY SCHOOL

*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព ចូលរួម លទ្ធផល សហគមន៍ សង្ឃឹម



ជំរាបមាតាបិតា/អាណាព្យាបាល,

## លទ្ធផលនៃការប្រឡងសាក(NAPLAN)

ខ្ញុំជឿជាក់ថា,មាតាបិតាបានទទួលលទ្ធផលនៃការប្រឡងសាកកាលពីសប្តាហ៍មុនរួចហើយ,ដូច្នេះបើលោកអ្នកមានសំណួរទាក់ទងនឹងការបកស្រាយពីលទ្ធផលនេះ,សូមទាក់ទងនឹងគ្រូរបស់កុមារ។យើងមានតែលទ្ធផលសិស្សម្នាក់ៗប៉ុណ្ណោះក្នុងពេលនេះ តែយើងខ្ញុំនឹងចែករំលែកលទ្ធផលសាលាទាំងមូលនៅថ្ងៃក្រោយ។

## កំណត់ប្រចាំថ្ងៃ:៣១/៧/២០២៣

៣១/៧: កិច្ចប្រជុំនៃក្រុមប្រឹក្សា:ម៉ោង៥:៣០:សាខខាងលិច
០១/៨: ថ្នាក់ទី៣និង៤ធ្វើដំណើរសិក្សានៅសាលាវូតលី
Playgroup នៅសាខាខាងលិច:ម៉ោង៩-១១ព្រឹក
កម្មវិធីឆ្លែស្ដិទ្ធស្គាលនៅសាខាខាងលិច
០២/៨: សកម្មភាពកីឡាសាលា:សាខាខាងលិច:វាយសី
សកម្មភាពកីឡាសាលាសាខាវ៉ាល្លី:លេងហ្គូល(golf)
០៤/៨: គោរពទង់ជាតិនៅសាខាខាងលិច:ម៉ោង២:៣០ល្ងាច
គោរពទង់ជាតិ:សាខាវ៉ាល្លី: ម៉ោង ៣:០០ល្ងាច ០៨/៨:
Playgroup នៅសាខាខាងលិច:ម៉ោង៩-១១ព្រឹក
១១/៨: ប្រកួតកីឡារវាងសាលាក្នុងតំបន់:ថ្នាក់ទី៥/៦

## គំរោងការណ៍ឆ្នាំ២០២៣:

គំរោងការណ៍សំរាប់ឆ្នាំ២០២៤កំពុងមានដំណើរការណ៍ទៅហើយ,ដូច្នេះបើមាតាបិតាបានដឹងគ្រួសារណាមានកូនអាយុ៥ឆ្នាំគិតដល់ថ្ងៃទី៣០/៤/២០២៤,សូមប្រាប់ឲ្យមកចុះឈ្មោះរៀន,ហើយបើមាតាបិតាដឹងថាឆ្នាំក្រោយកូនចៅលោកអ្នកមិនអាចមករៀននៅសាលាយើងទេ,ក៏សូមឲ្យយើងខ្ញុំដឹង ដែរ។ពត៌មាននេះសំខាន់ណាស់ចំពោះរចនាសម្ព័ន្ធថ្នាក់រៀន។

## ការបន្តឈប់សំរាក:

Mrs Rakic បានសំណូមពរសំរាកជាង៣សប្តាហ៍ដំបូងនៃត្រីមាសនេះ,ហើយយើងទាំងអស់គ្នានឹងស្វាគមន៍អ្នកគ្រូត្រឡប់មកវិញនៅថ្ងៃទី ៨ ខែកញ្ញា។Ms Stewart កំពុងបង្រៀនជំនួស,តែមិនអាចបន្តបន្តទៅទៀតបាន,ម្ល៉ោះហើយយើងខ្ញុំបានរក Ms Kodikara មកបង្រៀនជំនួស។

## រាត្រីសិល្បៈសាលា:

កុមារបានរៀនមេរៀនរាំជាមួយ STOMP ជាលើកដំបូង,ហើយកុមារចូលចិត្តយ៉ាងខ្លាំង។គ្រូកំពុងធ្វើការសម្រេចចិត្តអំពីកុមារត្រូវស្លៀកពាក់អ្វី, ម្ល៉ោះហើយគ្រួសារទាំងឡាយនឹងទទួលសំបុត្រដែលនឹងផ្ញើទៅផ្ទះរៀបរាប់ក្បោះក្បាយថាតើកុមារត្រូវស្លៀកពាក់អ្វី។ លោកអ្នកប្រហែលជាមានសម្លៀកបំពាក់ដែល សាលាត្រូវការខ្លះៗនៅផ្ទះស្រាប់ហើយៗយើងខ្ញុំក៏មិនអំពាវនាវឲ្យទិញអ្វីដែលថ្លៃឬពិបាករកនោះឡើយ។ គ្រូៗក៏មានថវិការដើម្បីទិញអ្វីដែលត្រូវការសំរាប់ឆាកសម្តែងរបស់ខ្លួនផងដែរ។យើងខ្ញុំរង់ចាំជួបមាតាបិតានិងគ្រួសារមករួមក្នុងរាត្រីសិល្បៈសាលានៅរោងមហាសាលស្ព្រីងវ៉េលនាថ្ងៃព្រហស្បត៍ទី១៨/៩។




## ការចូលនិវត្តរបស់ខ្ញុំ:

ដូចបានជំរាបជូនសហគមន៍សាលាយើងរួចហើយថា,ខ្ញុំនឹងសំរាកចំនួន៥ខែតាមក្របខ័ណ្ឌសេវាយូរឆ្នាំដែលនឹងចាប់ផ្តើមនៅថ្ងៃទី៧ ខែ សីហា, ក៏ប៉ុន្តែខ្ញុំក៏បានធ្វើការសម្រេចចិត្តដ៏លំបាកមួយដោយសម្រេចចិត្តថានឹងចូលនិវត្តក្រោយពីបានបំរើក្នុងវិស័យអប់រំជាង៤០ឆ្នាំមក។ខ្ញុំមានឯកសិទ្ធិដោយបានបង្រៀនសិស្សរាប់រយក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ,ហើយមានសិស្សមួយចំនួនថែមទាំងនាំកូនរបស់ខ្លួនមកចុះឈ្មោះរៀននៅសាលាយើងទៀត។ខ្ញុំបានក្លាយជាសមាជិកនៃសាលាបឋមសិក្សាស្ព្រីងប៉ាំងអស់រយៈពេល៣៤ឆ្នាំក្នុងឋានៈជាគ្រូ, ជាអ៊ីគ្គនាយកហើយទីបំផុតជានាយកសាលា។តើនេះជាដំណើរមួយដ៏អស្ចារ្យយ៉ាងណា? ខ្ញុំពិតជាបាននិយាយដោយស្មោះថា,ការជ្រើសរើសមុខងារជាគ្រូបង្រៀនគឺជាការសម្រេចចិត្តមួយដ៏ប្រពៃបំផុតក្នុងជីវិតរបស់ខ្ញុំ,តែសម្រេចចិត្តថាចូលនិវត្តគឺជាការលំបាកបំផុត។យើងមានសាលាមួយដ៏ល្អអស្ចារ្យ, ព្រោះនេះជាកន្លែងមួយដែលកុមារបានសាលាវាយតម្លៃខ្ពស់ហើយបង្រៀននូវអ្វីៗដែលអាចបង្រៀនបាន។សង្ឃឹមថានឹងបានជួបមាតាបិតា/អាណាព្យាបាលនៅពេលខ្ញុំនិយាយពាក្យសូមលាកុមារសាលាក្នុងខណៈគោរពទង់ជាតិដែលនឹងប្រព្រឹត្តឡើងនៅថ្ងៃសុក្រទី៤/៨ នៅសាខាខាងលិចវេលាម៉ោង២:៣០,សាខាវ៉ាល្លីម៉ោង៣:០០ល្ងាច។ ខ្ញុំនឹងមានពិធីជប់លៀងមួយសំរាប់ការចូលនិវត្តនៅត្រីមាសទី៤ក្រោយពីបានធ្វើទេសចរណ៍ជុំវិញប្រទេសអូស្ត្រាលីនិងប្រទេសអង់គ្លេស។សូមអរគុណចំពោះការគាំទ្ររបស់លោកអ្នកដល់ខ្លួនខ្ញុំក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ:-ខ្ញុំរីករាយបំផុតនឹងពេលវេលានៅសាលាស្ព្រីងប៉ាក។

**Julie Fisher :** នាយកសាលា

**សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Food Bank,Ardoch,Woodleigh School, OSH Club,Berry Street,Ed Connect**

# 100 Days Of School


















## តួបលក់វត្ថុអនុស្សាវរីយ៍នៃថ្ងៃឪពុក:

សាខាទាំងពីរនឹងចាត់ចែងតួបលក់វត្ថុអនុស្សាវរីយ៍នៃថ្ងៃឪពុកវេលាម៉ោង១១,នៅអគ្គា LEC សាខាវ៉ាល្លីថ្ងៃទី៣០/៧, ហើយសាខាខាងលិចក្នុងបណ្ណាល័យ,ថ្ងៃទី៣១/៧។ វត្ថុអនុស្សាវរីយ៍មានតម្លៃពី$៥-$១៥។យើងខ្ញុំសម្រេចចិត្តថានឹងរៀបចំថ្ងៃស្រស់ស្រូបពេលព្រឹកសំរាប់ថ្ងៃមាតាបិតារួមគ្នានៅត្រីមាសទី៤ជាជាងធ្វើដោយឡែកពីគ្នា,ហើយថ្ងៃនោះគឺត្រូវជាថ្ងៃចន្ទ ទី ៣០ ខែ តុលា វេលាម៉ោង៨:០០ព្រឹក។




### សេចក្តីរំឭកពីបុគ្គលិកការិយាល័យនៃសាខាខាងលិចនិងសាខាវ៉ាល្លី

- សូមឲ្យសាលាដឹងបើលេខទូរស័ព្ទឬអាស័យដ្ឋានរបស់លោកអ្នកបានប្តូរ
- បើកុមារឈប់រៀននៅថ្ងៃណាមួយ,សូមទូរស័ព្ទមកសាលាឬប្រើ Sentral app.
- សាលាបានទុករបស់ដែលកុមារបានធ្វើបាត់មួយចំនួននៅសាខាទាំងពីរ,សូមឆែកមើលបើកុមារមានបាត់អ្វីមួយ។
- សាលាចាប់ផ្តើមទទួលឈ្មោះថ្នាក់បំរុងឆ្នាំក្រោយហើយ,បើកុមារមានប្អូនៗត្រូវមករៀននៅឆ្នាំក្រោយ,សូមមកការិយាល័យយកប័ណ្ណចុះឈ្មោះ,បំពេញរួចយកមកសាលាវិញ។សំបុត្របញ្ជាក់ទទួលយកសិស្សជាផ្លូវការនឹងផ្ញើទៅផ្ទះនៅថ្ងៃទី១១ ខែ សីហា។
- បើលោកអ្នកដឹងញាតិមិត្តណាប្រាថ្នាមករៀននៅសាលាយើង,សូមប្រាប់ឲ្យមកទាក់ទងនឹងយើងខ្ញុំ។

សូមអរគុណពីបុគ្គលិកការិយាល័យ:

Hang,Fiona,Eleonora & Allison.




## កម្មវិធីហ្វឹកហ្វឺនជំនាញកីឡាបាល់ទាត់សំរាប់កុមារសាលា

- ណែនាំកម្មវិធីបាល់ទាត់ប្រកបដោយការរីករាយនិងសុវត្ថិភាព-រចនាឡើងសំរាប់កីឡាករថ្មីដែលមានអាយុពី៥-១១ឆ្នាំ ។

អាស្រ័យតាមចំនួនកុមារដែលចុះឈ្មោះចូលរួម,កម្មវិធីនឹងចែកចេញជា២ក្រុម-ក្រុមអាយុពី៥-៨ឆ្នាំនិងក្រុមអាយុពី៩-១១ឆ្នាំ។
ចំនួនកុមារច្រើនបំផុតក្នុង១ក្រុមគឺ២០-តិចបំផុតគឺ១០។

- រៀន១សប្តាហ៍ម្តងក្នុងរយៈពេល៨៥នាទីដើម្បីហ្វឹកហ្វឺនជំនាញតាមរយៈល្បែងលេងនិងបច្ចេកទេសក្នុងលក្ខណៈរួបរួមគ្នានឹងក្នុងបរិយាកាសដ៏កកក្តៅ។
- កីឡាករនិមួយៗមានពេលពេញបរិបូណ៌លេងបាល់,គោលបំណងចម្បងគឺហ្វឹកហ្វឺនមូលដ្ឋាននៃការស្ទាត់ជំនាញខាងចលនា។
- អ្នកចុះឈ្មោះថ្មីនិមួយៗនឹងបានទទួលស្បៀងចាប់ផ្តើមលេងបាល់ទាត់លើកដំបូងមីនីរូពីគណកម្មការបាល់ទាត់វិចតូរីយ៉ា។
- គ្រូបង្ហាត់និមួយៗមានប័ណ្ណបញ្ជាក់បានឆែកពិនិត្យសន្តិសុខក្នុងពេលធ្វើការជាមួយកុមារ។

តើកម្មវិធីនេះផ្តល់នូវគុណប្រយោជន៍យ៉ាងដូចម្តេចខ្លះដល់កុមារ?

- ស្គាល់មិត្តភក្តិថ្មីហើយអភិវឌ្ឍន៏ជំនាញខាងសង្គម
- អភិវឌ្ឍគុណតម្លៃនៃការងារជាក្រុម,សហប្រតិបត្តិការ,ការលេងដោយយុត្តិធម៌,ហើយការចេះគោរពអ្នកដទៃ
- អភិវឌ្ឍសមត្ថភាពរបស់កុមារដើម្បីឲ្យចេះធ្វើការសម្រេចចិត្តបានឆាប់រហ័ស,រយៈពេលប្រតិកម្មទៅលើបញ្ហាអ្វីមួយបានឆាប់រហ័សជាង
- រក្សាសុខភាពដោយចេះធ្វើសកម្មភាពនានា

**ពេលនិងទីកន្លែង:**

| | |
|---|---|
| Spring Parks PS<br>(Valley Campus) 27-39<br>Clarke Road<br>Springvale South Vic 3171 | ថ្ងៃអាទិត្យចាប់ផ្តើមទាំងឡាយ:<br>ពីម៉ោង១០:៣០-១១:១៥ ព្រឹក<br>ពេលហាត់ទាំង៨លើកចាប់ពីថ្ងៃអាទិត្យទី១៥/១០-១៧/១២ . កត់សំគាល់ (ថ្ងៃ៥/១១ និង ៣/១២ ឈប់សំរាកព្រោះបុណ្យប្រណាំងសេះ-គ្រូបង្ហាត់រវល់ |

**តម្លៃប៉ុន្មាន?** $១០០ចំពោះកុមារនិមួយៗ។

**តើចុះឈ្មោះយ៉ាងដូចម្តេច** ?តាមរយៈគេហទំព័រ Football Australia

សមាជិកថ្មី: https://membership.mygameday.app/regoform.cgi

formID=105799&programID=65805

សមាជិកចាស់: https://membership.mygameday.app/regoform.cgi?

formID=103181&programID=65806

បើចង់ជ្រាបពត៌មានពិស្តារឬប្រាថ្នាទាក់ទងនឹងយើងខ្ញុំសូមចូលគេហទំព័រ:

Miniroos - Kingston Royals Futsal Club



# KEYSBOROUGH COLLEGE
# EXTENSION AND ENRICHMENT PROGRAM

## កម្មវិធីពង្រឹងនិងពង្រីក



## កម្មវិធីថ្មីសំរាប់ឆ្នាំ២០២៤

យើងខ្ញុំមានក្ដីរំភើបនឹងណែនាំជូនលោកអ្នកកម្មវិធីពង្រឹងនិងពង្រីកនៃវិទ្យាល័យឃីបរ៉ូ,ដែលបានចាត់ចែងឡើងសំរាប់សិស្សដែលមានមហិច្ឆតាខ្ពស់បំផុតរបស់យើង។ឆ្នាំ២០២៤,វិទ្យាល័យយើងនឹងចាប់ផ្ដើមកម្មវិធីជ្រើសរើសសិស្សថ្នាក់ទី៧ដែលស្របលក្ខ័ណ្ឌហើយមានសមត្ថភាពខ្ពង់ខ្ពស់ដើម្បីប្រឈមមុខនឹងគណិតសាស្ត្រនិងភាសាអង់គ្លេស។

## ជ្រើសរើសផ្លូវដ៏ត្រឹមត្រូវ

យើងខ្ញុំយល់ថាការជ្រើសរើសផ្លូវដ៏ត្រឹមត្រូវជាការសម្រេចចិត្តមួយដ៏សំខាន់។កម្មវិធីរបស់សាលាយើងបានរៀបចំឡើងដើម្បីផ្ដល់ឲ្យកូនលោកអ្នកនូវចំណេះនិងការស្ទាត់ជំនាញចាំបាច់ដើម្បីឲ្យលទ្ធផលដែលទទួលបានរបស់កូនលោកអ្នកបានល្អខ្ពស់ត្រដែតក្នុងការខិតខំរៀនសូត្ររបស់សាមីខ្លួននៅអនាគត។ យើងខ្ញុំសូមអញ្ជើញលោកអ្នកមកស្វែងយល់ថាតើកម្មវិធីរបស់យើងខ្ញុំនេះនឹងផ្ដល់ជូនកូនលោកអ្នកនូវអ្វីខ្លះ, ហើយពិចារណាពីរបៀបដែលកម្មវិធីនេះអាចជួយកូនលោកអ្នកឲ្យយល់ពីសមត្ថភាពរបស់ខ្លួនខ្ពស់ដល់កំរិតណា។ដើម្បីចង់យល់បន្ថែមអំពីកម្មវិធីនេះ,សូមចូលទៅកាន់គេហទំព័ររបស់វិទ្យាល័យឬទាក់ទងសាលាដោយផ្ទាល់,ហើយសមាជិកនៃក្រុមការងាររបស់យើងខ្ញុំរីករាយនឹងពន្យល់ជូនពីអត្ថប្រយោជន៏ដែលកូនលោកអ្នកនឹងបានទទួល។



## សូមចុះឈ្មោះ

កាចុះឈ្មោះប្រព្រឹត្តទៅឡើងដោយសេរីដោយឥតគិតថ្លៃចំពោះកម្មវិធីពង្រឹងនិងពង្រីកនៅវិទ្យាល័យឃីបរ៉ូ,ក៏ប៉ុន្តែកូនរបស់លោកអ្នកត្រូវចុះឈ្មោះរៀននៅវិទ្យាល័យយើងខ្ញុំនៅឆ្នាំសិក្សា២០២៤ដើម្បីគ្រប់លក្ខណៈធ្វើតេសត៍,ព្រោះនេះជាលក្ខ័ណ្ឌមួយធ្វើឡើងដើម្បីសន្មត់ថាតើកូនលោកអ្នកសាកសមទៅនឹងកម្មវិធីនេះឬទេ។ សូមចុះឈ្មោះតាមរយៈ QR Code ដូចនៅខាងក្រោមនេះឬតាមរយៈគេហទំព័រ របស់វិទ្យាល័យឃីបរ៉ូ។
ការចុះឈ្មោះនឹងបញ្ចប់នៅថ្ងៃ ទី៧/៨/២០២៣

ការប្រឡងនឹងចាប់ផ្ដើមពីម៉ោង៩:០០-១១:៣០ព្រឹក
ថ្ងៃសៅរ៏ ទី១២ សីហា ២០២៣
នៅវិទ្យាល័យឃីបរ៉ូ, សាខា អាកាស៊ីយ៉ា
(Keysborough College, Acacia Campus)
28 Isaac Rd,Keysborough,3173

KEYSBOROUGH COLLEGE
RESPECT • EXCELLENCE • DIVERSITY

## កីឡា- កីឡាកាយវប្បកម្ម

ថ្នាក់បំរុងដល់ថ្នាក់ទី២រីករាយក្នុងការៀន កីឡាកាយវប្បកម្ម។ កុមាបានរៀនរបៀបរមៀលខ្លួនទៅមុខគ្រប់ជុំដោយ សុវត្ថិភាពហើយលោតផ្លោះទៅមុខដោយច្រត់ដៃទៅលើ តុផ្តេក។

កុមារក៏បានផ្តោតអារម្មណ៏ទៅលើបច្ចេកទេសលំនឹងខ្លួនដោយលោតលើបន្ទះរឹស័រ(Trampoline).





## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 2 | Week 3 |
|---|---|---|
| FA | Ben-Aisy | Tiara-Kosal |
| 1/2 A | Humairah | Ayden |
| 1/2 B | Stephanie | Abby |
| 3/4 A | Amelia | Melinda |
| 3/4 B | Lyra | Lee-Lyna |
| 5/6 A | Celeste | Anamercy |
| 5/6 B | Tiffany | Everand |
| Art | | |
| PE | Alayp | Solika 1/2A |
| Spanish | | |

### VALLEY CAMPUS

| Grade | Week 2 | Week 3 |
|---|---|---|
| FL | Jaanvi | Ellice |
| 1/2 L | Acil | Kieran |
| 1/2 M | Shane | Khang |
| 3/4 L | | Aliza |
| 3/4 M | Rocky | Ben |
| 5/6 L | Linee | Halitta |
| 5/6 M | Mia | Rosella |
| Art | Jaydent | |
| PE | Branden | Mia-Cecilia |
| Spanish | Ryzo | |